# ជំពូកទី៤

# អត្រានុកូលដ្ឋានមរណភាព

# ជំពូកទី៤
# អត្រានុកូលដ្ឋានមរណភាព

## ៤.១.សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

### ៤.១.១. សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានមរណភាព (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ២០០២-២០០៧)

ចំពោះសៀវភៅចម្លងសំបុត្រមរណភាព និងសៀវភៅចម្លងសំបុត្របញ្ជាក់មរណភាព មិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

### ៤.១.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព រួមមាន ៖

- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៧)
- សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំសម្រាប់ចម្លងនៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ចម្លងនៅ ក្រុង ស្រុក ខណ្ឌ និងនៅក្រសួងមហាផ្ទៃ)
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព (សម្រាប់ចម្លងនៅក្រុង ស្រុក ខណ្ឌ និងនៅក្រសួងមហាផ្ទៃ)

## ៤.២. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព

**ជំហានសំខាន់ៗ នៃការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព ÷**

- ពិនិត្យឯកសារដែលអ្នកសុំចុះបញ្ជីនាំមកជាមួយ (លិខិតជូនដំណឹងមរណភាព សៀវភៅគ្រួសារ...)
- សរសេរចូលក្នុងបញ្ជីភ្លោះនៃសៀវភៅអត្រានុកូលដ្ឋាន (ទាំងពីរក្បាល)
- ឱ្យអ្នកសុំចុះបញ្ជី (អ្នករាយការណ៍) ពិនិត្យទិន្នន័យដែលបានសរសេរចូលឱ្យបានច្បាស់លាស់ បើសិនជាគាត់ចេះអក្សរ ឬអានឱ្យគាត់ស្តាប់ បើសិនជាគាត់មិនចេះអក្សរ មុននឹងអនុញ្ញាតឱ្យអ្នកសុំចុះបញ្ជី ផ្តិតស្នាមមេដៃនៅលើបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន
- អនុញ្ញាតឱ្យអ្នកសុំចុះបញ្ជីផ្តិតមេដៃស្តាំត្រង់ពាក្យអ្នករាយការណ៍ (ផ្តិតស្មើៗមិនឱ្យល្បើទេ)
- ស្រង់ទិន្នន័យពីក្នុងសៀវភៅសរសេរចូលទៅក្នុងសំបុត្រ
- ចុះហត្ថលេខា បោះត្រា និងផ្តល់សំបុត្រទៅឱ្យអ្នកស្នើសុំចុះបញ្ជី ព្រមទាំងបញ្ជាក់ ប្រាប់គាត់ថា សូមរក្សាទុកសំបុត្រនេះ ឱ្យបានល្អព្រោះច្បាប់ដើមមានតែមួយ និងចេញតែម្តងគត់ក្នុងមួយជីវិត។
- ករណីចង់យកទៅប្រើប្រាស់ដោយប្រការណាមួយ ត្រូវសុំចម្លងនៅឃុំ សង្កាត់ (ក្នុងឆ្នាំ) និងចម្លងនៅសាលាក្រុង ស្រុក ខណ្ឌ ឬក្រសួងមហាផ្ទៃ (ឆ្លងឆ្នាំ)។

☞ ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្នុងក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់**ឱ្យទាន់ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព**។

☞ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ចាប់ពីថ្ងៃទទួលមរណភាព។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្តល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ ជូនចំពោះក្រុមគ្រួសារ ឬសាច់ញាតិសន្តានដែលមករាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពឱ្យអ្នកស្លាប់ ក្នុងរយៈពេលកំណត់ ១៥ថ្ងៃ។

☞ ករណីមានអ្នកស្លាប់ទុកឱ្យហួសរយៈពេលដែលកំណត់ដោយច្បាប់ ត្រូវអនុវត្តដូចខាងក្រោម៖

- បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល**១៥ថ្ងៃ** នៅក្នុងឆ្នាំពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់សាមីនៃលំនៅឋានពិតប្រាកដរបស់អ្នកស្លាប់។ ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនេះត្រូវបង់ថ្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋានចំនួន **១.០០០រៀល** (មួយពាន់រៀលគត់) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង **៣.០០០រៀល** (បីពាន់រៀលគត់) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តទាំង០៥ខាងលើ។
- បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។

☞ បើមានសាលក្រមបញ្ជាក់ពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព។

**បញ្ជាក់ ÷**

☞ ចំពោះអ្នកស្លាប់នៅចុងខែធ្នូ នៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល១៥ថ្ងៃអាចឆ្លងចូលឆ្នាំបន្ទាប់ ក្រុមគ្រួសារនៃអ្នកស្លាប់អាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅក្នុងឆ្នាំកំពុងអនុវត្ត ឬនៅឆ្នាំបន្ទាប់បាន

☞ ចំពោះអ្នកស្លាប់នៅចុងខែធ្នូ នៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល១៥ថ្ងៃឆ្លងចូលឆ្នាំបន្ទាប់ តែទុកឱ្យហួសរយៈពេលកំណត់១៥ថ្ងៃ ក្រុមគ្រួសារនៃអ្នកស្លាប់អាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឆ្នាំបន្ទាប់បាន ដោយត្រូវអនុវត្តទៅតាមបែបបទនៃករណីអ្នកទទួលមរណភាពទុកឱ្យហួសរយៈពេល ១៥ថ្ងៃ។

**គូសបំព្រួញមរណភាពឆ្លងឆ្នាំ និងឆ្លងឆ្នាំ**




### ៤.២.១. លិខិតស្នាមនានាដែលពាក់ព័ន្ធនឹងសព

**ក). ករណីការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេលកំណត់១៥ថ្ងៃ**

☞ អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម ៖

- **លិខិតជូនដំណឹងមរណភាព** ៖
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
  - <u>លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ</u>
  - លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ

– លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព បើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកស្លាប់
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)

សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់ ត្រូវមានឯកសារបន្ថែមទៀត ៖

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលនៅមានសុពលភាព
- ទិដ្ឋាការ ឬប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅមានសុពលភាព
- ករណីឯកសារណាមួយខាងលើនេះបាត់បង់ ត្រូវមានលិខិតស្នាមនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់ ។

**បញ្ជាក់ ៖ បើលិខិតស្នាមណាមួយមានការសង្ស័យ មន្ត្រីអត្រានុកូលដ្ឋានត្រូវទំនាក់ទំនងជាមួយនឹងសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងលិខិតស្នាមនោះ។**

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកនូវលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងសព ក្នុងសំណុំឯកសារមរណភាពនៅឃុំ ឬសង្កាត់ ៖

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

**ខ). ករណីការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព ហួសរយៈពេលកំណត់១៥ថ្ងៃ ក្នុងឆ្នាំ**

☞ អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រា-នុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម ៖

**លិខិតជូនដំណឹងមរណភាព ៖**

– លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព បើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។

• សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ ឬ
• អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកស្លាប់
• សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)។
• សៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកមកប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកនូវលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងសព ក្នុងសំណុំឯកសារមរណភាពនៅឃុំ ឬសង្កាត់ ៖

• ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពរបស់គ្រួសារនៃអ្នកស្លាប់
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ ឬ
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ឬ
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ឬ
• លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
• លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព ឬ
• លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

**គ). ករណីការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាពទុកឱ្យហួសឆ្នាំ**

បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសាលក្រមពីតុលាការរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូល-ដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។

**អ្នកប្តឹងសុំត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម៖**

- សៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំ
- សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការរាជធានី ខេត្តសាមី
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់ ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកប្តឹងសុំ (ប្រសិនបើមាន) ។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព ៖

- សាលក្រមបញ្ជាក់ពីមរណភាពរបស់សាលាដំបូងរាជធានី ខេត្ត សាមី

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក ។

### ៤.២.២. ការសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសព

☞ ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ច នៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសពក្នុងករណីអ្នកស្លាប់ដោយចាស់ជរា ឬដោយជំងឺ (បញ្ជាក់ពីប្រភេទជំងឺជាក់លាក់) ឬដោយគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

☞ បើអ្នកស្លាប់ដោយជំងឺឆ្លងរាតត្បាតដែលអាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយ-ការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ ។

☞ បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យពីអំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណាដែលបានឃើញ ឬដឹងឮហេតុការណ៍នោះ ត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចពីកន្លែងនៃអ្នកស្លាប់នោះ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយឱ្យបានទាន់ពេលវេលា ។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រា-នុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ។

☞ បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ណាមួយ បានស្លាប់នៅឃុំ សង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលអ្នកស្លាប់បានរស់នៅមុនពេលស្លាប់ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់នោះ ឱ្យទៅយកសពមកធ្វើបុណ្យ និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ សង្កាត់ដែលអ្នកស្លាប់នោះបានរស់នៅជាប់លាប់មុនពេលស្លាប់។

☞ បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវចាត់ចែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ សង្កាត់នោះ។

☞ នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព ដើម្បីសុំលិខិតអនុញ្ញាតធ្វើបុណ្យបូជា ឬបញ្ចុះសព សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសុំសំបុត្រមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យមើលលិខិតស្នាម (ដូចមានបរិយាយនៅចំណុច ៤.២.១) ឱ្យបានច្បាស់លាស់ បើឃើញត្រឹមត្រូវទៅតាមការកំណត់ហើយ ត្រូវសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពទៅតាមលក្ខណៈនៃការស្លាប់នោះ។

### ៤.២.៣. ការសរសេរចុះបញ្ជីមរណភាព

#### ក).សម្រាប់ប្រជាពលរដ្ឋខ្មែរ

☞ នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីមរណភាពចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពភ្លោះ។

☞ របៀបសរសេរចុះបញ្ជីមរណភាព នៃសៀវភៅអត្រានុកូលដ្ឋានមរណភាពដែលបានចុះលេខ និងចុះឆ្នាំរួចហើយ មានដូចខាងក្រោម ៖

១). រាជធានី ខេត្ត ៖ ត្រូវសរសេរដូចក្របមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

២). ក្រុង ស្រុក ខណ្ឌ ៖ ត្រូវសរសេរដូចក្របមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

៣). ឃុំ សង្កាត់ ៖ ត្រូវសរសេរដូចក្របមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

៤). លេខ ៖ ត្រូវសរសេរលេខរៀងបញ្ជីមរណភាព។ លេខរៀងបញ្ជីមរណភាពដែលត្រូវសរសេរចុះ គឺសរសេរ ២ខ្ទង់ ចាប់ផ្ដើមពីលេខ ០១ ជាបន្តបន្ទាប់ ដោយសរសេរជាលេខខ្មែរ។

៥). សៀវភៅមរណភាពលេខ ៖ត្រូវសរសេរលេខសៀវភៅដូចលេខដែលចុះនៅក្របមុខនៃសៀវភៅអត្រា-នុកូលដ្ឋានមរណភាពដែលកំពុងសរសេរ។

៦). ឆ្នាំ ៖ ត្រូវសរសេរឆ្នាំដែលចុះនៅក្របមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាពដែលកំពុងសរសេរ។

៧). នាមត្រកូល ៖ ត្រូវសរសេរនាមត្រកូលរបស់អ្នកស្លាប់។

បញ្ជាក់ ៖ បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន នៅត្រង់ខ្ទង់ “នាមត្រកូល” ទុកចំហចោល ដូច្នេះនៅត្រង់ខ្ទង់ “នាមត្រកូល” នៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវទុកចំហចោលដែរ។

៨). នាមខ្លួនសព ៖ ត្រូវសរសេរនាមខ្លួនរបស់អ្នកស្លាប់។

៩). ភេទ ៖ ត្រូវសរសេរភេទរបស់អ្នកស្លាប់ ។

១០). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់អ្នកស្លាប់ ។

១១). ជាអក្សរឡាតាំង ៖

- នាមត្រកូល ៖ ត្រូវសរសេរនាមត្រកូលអ្នកស្លាប់ជាអក្សរឡាតាំង ។
- នាមខ្លួន ៖ ត្រូវសរសេរនាមខ្លួនអ្នកស្លាប់ជាអក្សរឡាតាំង ។

បញ្ជាក់ ៖ បើពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកឱ្យនៅទំនេរពុំចាំបាច់សរសេរក៏បាន

១២). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកស្លាប់ ដោយសរសេរថ្ងៃជាអក្សរខ្មែរ ទីជាលេខខ្មែរ ខែជាអក្សរខ្មែរ តាមសុរិយគតិ និងឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ ។

១៣). ទីកន្លែងកំណើត ៖ ត្រូវសរសេរឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និង ប្រទេសរបស់អ្នកស្លាប់ ។

១៤). ស្ថានភាពសព ៖ ត្រូវបញ្ជាក់អំពីអ្នកស្លាប់ បើនៅលីវត្រូវសរសេរ “លីវ” បើមានប្តី ត្រូវសរសេរ “មានប្តី” បើមានប្រពន្ធ ត្រូវសរសេរ “មានប្រពន្ធ” បើពោះម៉ាយ ត្រូវសរសេរ “ពោះម៉ាយ” បើមេម៉ាយ ត្រូវសរសេរ “មេម៉ាយ” ។

១៥). មុខរបររបស់សពមុនពេលស្លាប់ ៖ ត្រូវសរសេរតែមុខរបររបស់អ្នកស្លាប់មុនពេលស្លាប់ប៉ុណ្ណោះ ។

១៦). ទីលំនៅរបស់សពមុនពេលស្លាប់ ៖ ត្រូវសរសេរតែទីលំនៅរបស់អ្នកស្លាប់មុនពេលស្លាប់ប៉ុណ្ណោះ អំពី លេខផ្ទះ លេខផ្លូវ (បើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និង ប្រទេស ។

១៧). លេខអត្តសញ្ញាណប័ណ្ណ ៖ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណនៃអ្នកស្លាប់ (ប្រសិនបើមាន) ។

១៨). ថ្ងៃ ខែ ឆ្នាំដែលស្លាប់ ៖ ត្រូវសរសេរថ្ងៃជាអក្សរខ្មែរ ទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ ។ **ឧទាហរណ៍:** ថ្ងៃច័ន្ទ ទី២០ ខែមករា ឆ្នាំ២០១៤ ។

១៩). ទីកន្លែងដែលស្លាប់ ៖ ត្រូវសរសេរពីទីកន្លែងដែលអ្នកស្លាប់បានស្លាប់នៅទីនោះ ត្រូវសរសេរឈ្មោះ ភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេសកម្ពុជា ។

**ឧទាហរណ៍** ÷ ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ។

២០). មូលហេតុដែលស្លាប់តាមបណ្តឹងអ្នករាយការណ៍ ៖ ត្រូវសរសេរអំពីមូលហេតុលម្អិតច្បាស់លាស់ ពិតប្រាកដនៃអ្នកស្លាប់ តាមការផ្តល់ព័ត៌មានពីអ្នករាយការណ៍ ។ បើស្លាប់ដោយជំងឺ ត្រូវសរសេរ បញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទជំងឺ (មើលចំណុច៤.៣.៤ ទំព័រ១៥៩) ។

**ឪពុកសព**

**បញ្ជាក់** ៖

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ពុំមានសរសេរអ្វីនៅផ្នែកឪពុក ដូច្នេះ នៅផ្នែកឪពុកនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវទុកឱ្យនៅទំនេរដែរ (មិនសរសេរ អ្វីទាំងអស់) ។

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន សរសេរ "មិនស្គាល់" នៅផ្នែកឪពុក ដូច្នេះនៅផ្នែកឪពុកនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវសរសេរ "មិនស្គាល់" ដែរ ។

២១). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនរបស់ឪពុកនៃអ្នកស្លាប់ ។

២២). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់ឪពុកនៃអ្នកស្លាប់ ។

២៣). រស់ ឬស្លាប់ ៖ បើនៅរស់ត្រូវឆូតចោល "ស្លាប់" បើស្លាប់ត្រូវឆូតចោល "រស់" ។

២៤). ជាអក្សរឡាតាំង ៖ សរសេរជាអក្សរឡាតាំងនូវនាមត្រកូល និងនាមខ្លួនរបស់ឪពុកនៃអ្នកស្លាប់ ។ បើពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកឱ្យនៅទំនេរពុំចាំបាច់សរសេរក៏បានដែរ ។

២៥). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកនៃអ្នកស្លាប់ ។

**ឧទាហរណ៍** ÷ ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩១០ ។

**ម្ដាយសព**

**បញ្ជាក់** ៖

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ពុំមានសរសេរអ្វីនៅផ្នែកម្ដាយ ដូច្នេះ នៅផ្នែកម្ដាយនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវទុកឱ្យនៅទំនេរដែរ (មិនសរសេរអ្វីទាំងអស់) ។
- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន សរសេរ "មិនស្គាល់" នៅផ្នែកម្ដាយ ដូច្នេះ នៅផ្នែកម្ដាយនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវសរសេរ "មិនស្គាល់" ដែរ ។

២៦). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនរបស់ម្ដាយនៃអ្នកស្លាប់ ។

២៧). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់ម្ដាយនៃអ្នកស្លាប់ ។

២៨). រស់ ឬស្លាប់ ៖ បើនៅរស់ត្រូវឆូតចោល "ស្លាប់" បើស្លាប់ត្រូវឆូតចោល "រស់" ។

២៩). ជាអក្សរឡាតាំង ៖ ត្រូវសរសេរជាអក្សរឡាតាំងនូវនាមត្រកូល និងនាមខ្លួនរបស់ម្ដាយនៃអ្នកស្លាប់ ។ បើពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកឱ្យនៅទំនេរ ពុំចាំបាច់សរសេរក៏បាន ។

៣០). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់ម្ដាយនៃអ្នកស្លាប់ ។

**ឧទាហរណ៍** ÷ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩១២ ។

**អ្នករាយការណ៍អំពីសព**

៣១). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួននៃអ្នកមករាយការណ៍អំពីអ្នកស្លាប់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព ។

៣២). ភេទ ៖ ត្រូវសរសេរភេទរបស់អ្នករាយការណ៍ ។

៣៣). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់អ្នករាយការណ៍ ។

៣៤). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នករាយការណ៍ ។

៣៥). ត្រូវជាអ្វីនឹងសព ៖ ត្រូវសរសេរពីការពាក់ព័ន្ធ ជាឪពុក ម្ដាយ ឬកូន ឬសាច់ញាតិសន្ដាន ឬអ្នកជិតខាងនៃអ្នកស្លាប់។

**ឧទាហរណ៍** ÷ បើជាកូនបង្កើតត្រូវសរសេរ "កូនបង្កើត" បើជាប្រពន្ធត្រូវសរសេរ "ប្រពន្ធ" បើជាមាបង្កើតត្រូវសរសេរ "មាបង្កើត" ។

៣៦). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីមុខរបរបច្ចុប្បន្នរបស់អ្នករាយការណ៍។

៣៧). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីទីលំនៅបច្ចុប្បន្នរបស់អ្នករាយការណ៍អំពីលេខផ្ទះ លេខផ្លូវ (ប្រសិនបើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស។

៣៨). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណរបស់អ្នករាយការណ៍ (ប្រសិនបើមាន)។

**បញ្ជាក់:** ពេលដែលសរសេរបំពេញក្នុងខ្ទង់ខាងលើនេះចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍ពិនិត្យមើល។ ក្នុងករណីអ្នកមករាយការណ៍មិនចេះអក្សរ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវអានឱ្យអ្នកមករាយការណ៍ស្ដាប់គ្រប់ចំណុចទាំងអស់ ហើយបើឃើញថាត្រឹមត្រូវ និងឯកភាពហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តដូចខាងក្រោម ៖

៣៩). ស្នាមមេដៃស្ដាំរបស់អ្នករាយការណ៍ ៖ ត្រូវផ្ដិតមេដៃស្ដាំរបស់អ្នករាយការណ៍អំពីមរណភាពទុកជាភស្ដុតាង ក្រោយពេលឯកភាពថាត្រឹមត្រូវ។ បន្ទាប់មកសរសេរឈ្មោះរបស់អ្នករាយការណ៍ពីក្រោមស្នាមមេដៃ។

៤០). ធ្វើនៅ-----ថ្ងៃទី--- ខែ----- ឆ្នាំ----- ៖ ត្រូវសរសេរឈ្មោះនៃឃុំ ឬសង្កាត់ ទីកន្លែងដែលសុំចុះសៀវភៅអត្រានុកូលដ្ឋាន និង ចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរ តាមសុរិយគតិ និងឆ្នាំជាលេខខ្មែរតាមគ្រិស្តសករាជ។ **ឧទាហរណ៍** ÷ ធ្វើនៅកោះកែវ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤។

៤១). មន្ត្រីអត្រានុកូលដ្ឋាន ៖ ត្រូវសរសេរពីក្រោមពាក្យមន្ត្រីអត្រានុកូលដ្ឋានថា មេឃុំ ឬចៅសង្កាត់ បើមេឃុំ ឬចៅសង្កាត់អវត្តមាន ជំទប់ ចៅសង្កាត់រង និងទទួលសិទ្ធិតាមឋានានុក្រមតាមរយៈលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីមេឃុំ ចៅសង្កាត់។ ក្នុងករណីនេះ ត្រូវសរសេរពីក្រោមពាក្យ "មន្ត្រីអត្រានុកូលដ្ឋាន" ដាក់ថា "មេឃុំស្ដីទី" ឬ "ចៅសង្កាត់ស្ដីទី"។

៤២). ហត្ថលេខា និងត្រា ៖ ត្រូវចុះហត្ថលេខាមន្ត្រីអត្រានុកូលដ្ឋាន (ក្រោមពាក្យមេឃុំ ចៅសង្កាត់ ឬមេឃុំ ចៅសង្កាត់ស្ដីទី) សរសេរឈ្មោះ ឬបោះត្រាឈ្មោះអ្នកចុះហត្ថលេខាពីក្រោមហត្ថលេខា រួចបោះត្រាឃុំ ឬសង្កាត់ ពីលើផ្នែកខាងឆ្វេងមួយភាគបីនៃហត្ថលេខា និងបោះត្រាឱ្យត្រង់តួអក្សរ (ត្រាប្រើទឹកល័ក្ខពណ៌ក្រហម)។

**បញ្ជាក់** ÷ ចំពោះពិរុទ្ធជន ឬទណ្ឌិតដែលស្លាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ

☞ ករណីមានពិរុទ្ធជន ឬអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ អ្នកទទួលខុសត្រូវនៃពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែនោះ ត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅមន្ត្រីអត្រានុកូលដ្ឋាន នៃលំនៅឋានអចិន្ត្រៃយ៍របស់ពិរុទ្ធជន ឬទណ្ឌិតនោះ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។

☞ មុខរបរ ត្រូវដាក់មុខរបរមុនពេលជាប់ជាពិរុទ្ធជន ឬទណ្ឌិត។

☞ ទីកន្លែងស្លាប់ ត្រូវដាក់ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស ដែលពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែតាំងនៅ។ **ឧទាហរណ៍** ÷ បើស្លាប់នៅពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ ម១ ត្រូវសរសេរថា ៖ ភូមិកំរៀង សង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**បញ្ជាក់** ÷ សាកសពដែលមិនស្គាល់

ចំពោះសាកសពដែលមិនស្គាល់ មន្ត្រីអត្រានុកូលដ្ឋាន ក៏ត្រូវសរសេរចុះក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពដែរ ដោយសរសេរយោងកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចនៅរឹមទំព័រខាងឆ្វេងនៃបញ្ជីមរណភាព ហើយសរសេរចុះនៅក្នុងបញ្ជីមរណភាព តាមខ្លឹមសារនៃកំណត់ហេតុរបស់សមត្ថកិច្ច ដូចជា ៖

- ភេទ
- ទីកន្លែងស្លាប់ ៖ យកកន្លែងដែលឃើញសាកសព
- មូលហេតុស្លាប់តាមបណ្ដឹងរបស់អ្នករាយការណ៍ ៖ យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច
- ថ្ងៃ ខែ ឆ្នាំ ស្លាប់ ៖ យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចច្បាប់ចម្លង០១ច្បាប់ ជាឯកសារនៅសាលាឃុំ សង្កាត់។

**ឧទាហរណ៍ ៤.១** ÷ ការសរសេរចុះបញ្ជីមរណភាព លេខ ០៣ តាមអត្ថបទឧទាហរណ៍ខាងក្រោម ៖

ថ្ងៃពុធ ទី២២ ខែមករា ឆ្នាំ២០១៤ លោក សោម សារិទ្ធ បានទៅជួបមន្ត្រីអត្រាកូលដ្ឋានឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ដើម្បីសុំច្បាប់ធ្វើបុណ្យបូជាសព និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពជូនម្ដាយបង្កើតរបស់គាត់ដែលស្លាប់ពីថ្ងៃច័ន្ទ ទី២០ ខែមករា ឆ្នាំ២០១៤ នៅផ្ទះរបស់គាត់។

ប្រវត្តិតួអង្គទាក់ទងនឹងមរណភាព

១). លោក សោម សារិទ្ធ ៖

លោក សោម សារិទ្ធ មានសញ្ជាតិខ្មែរ កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៤៩ នៅភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង។ គាត់ជាកសិករគ្មានអត្តសញ្ញាណប័ណ្ណ ហើយមានទីលំនៅបច្ចុប្បន្ន នៅភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល។

២). លោកយាយ ស៊ឹម វណ្ណា ជាម្ដាយលោក សោម សារិទ្ធ ៖

លោកយាយ ស៊ឹម វណ្ណា មានសញ្ជាតិខ្មែរ កើតថ្ងៃច័ន្ទ ទី២៦ ខែតុលា ឆ្នាំ១៩៣១ នៅភូមិបឹង ឃុំស្វាយអន្ទរ

ស្រុកព្រៃវែង ខេត្តព្រៃវែង មុនពេលស្លាប់គាត់ជាកសិករ រស់នៅជាមួយកូនឈ្មោះ សោម សារិទ្ធ។ គាត់ស្លាប់នៅ ថ្ងៃច័ន្ទ ទី២០ ខែមករា ឆ្នាំ២០១៤ ដោយជំងឺលើសឈាម។ រីឯចំណែកប្ដីរបស់គាត់នៅរស់នៅឡើយ។

៣). លោក ស៊ឹម សារឿន ជាឪពុកលោកយាយ ស៊ឹម វណ្ណា ៖

លោក ស៊ឹម សារឿន មានសញ្ជាតិខ្មែរ កើតថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩១០ គាត់ស្លាប់ក្នុងឆ្នាំ១៩៧៧។

៤). លោកយាយ ស្រី នាង ជាម្ដាយលោកយាយ ស៊ឹម វណ្ណា ៖

លោកយាយ ស្រី នាង មានសញ្ជាតិខ្មែរ កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩១២ គាត់ស្លាប់ក្នុងឆ្នាំ១៩៧៧។

ផ្អែកតាមខ្លឹមសារខាងលើនេះ ចូរសរសេរចុះបញ្ជីមរណភាព។

**~~រាជធានី~~ ខេត្ត** (១).......... *កណ្ដាល* ......

**~~ក្រុង~~ ស្រុក ~~ខណ្ឌ~~** (២)........ *ល្វាឯម* .........

**ឃុំ ~~សង្កាត់~~** (៣)......... *កោះកែវ* ...........

**លេខ** (៤)........... *០៣* ...............................

**សៀវភៅមរណភាពលេខ** (៥)....០១/២០១៤....

**ឆ្នាំ** (៦)....... *២០១៤* ....................................

# បញ្ជីមរណភាព

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | *ស៊ឹម* | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនសព (៨) | | *វណ្ណា* | *ស្រី* | *ខ្មែរ* |
| ជាអក្សរឡាតាំង (១១) | នាមត្រកូល | SIM | | |
| | នាមខ្លួនសព | *VANNA* | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | | |
| ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ........... *ភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា* .................<br>........................................................................................ | | |
| ស្ថានភាពសព (១៤)<br>នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *មានប្ដី* | | |
| មុខរបររបស់សពមុនពេលស្លាប់ (១៥) | | *កសិករ* | | |
| ទីលំនៅរបស់សពមុនពេលស្លាប់ (១៦) | | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | |
| លេខអត្តសញ្ញាណប័ណ្ណ (១៧) | | *គ្មាន* | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៨) | | *ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤* | | |
| ទីកន្លែងស្លាប់ (១៩) | | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | |
| មូលហេតុស្លាប់តាមបណ្ដឹងរបស់អ្នករាយការណ៍ (២០) | | *លើសឈាម* | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (២១) | | *ស៊ឹម សារឿន* | សញ្ជាតិ *ខ្មែរ* (២២) | |
| ជាអក្សរឡាតាំង (២៤) | | SIM SAROEUN | ~~រស់~~ ឬ ស្លាប់ (២៣) | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | | |
| នាមត្រកូល និង នាមខ្លួនម្ដាយសព (២៦) | | *ស្រី នាង* | សញ្ជាតិ *ខ្មែរ* (២៧) | |
| ជាអក្សរឡាតាំង (២៩) | | SREY NEANG | ~~រស់~~ ឬ ស្លាប់ (២៨) | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣០) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | | |
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព (៣១) | | *សោម សារិទ្ធ* | ភេទ (៣២) | សញ្ជាតិ (៣៣) |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៤) | | *ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៤៩* | *ប្រុស* | *ខ្មែរ* |
| ត្រូវជាអ្វីនឹងសព (៣៥) | | *កូនបង្កើត* | | |
| មុខរបរបច្ចុប្បន្ន (៣៦) | | *កសិករ* | | |
| ទីលំនៅបច្ចុប្បន្ន (៣៧) | | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣៨) | | *គ្មាន* | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

(៤០) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*

(៣៩) **ស្នាមមេដៃស្ដាំអ្នករាយការណ៍**

*សោម សារិទ្ធ*

(៤១) **មន្ត្រីអត្រានុកូលដ្ឋាន**

*មេឃុំ*

(៤២) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

**ខ).សម្រាប់ជនបរទេស ឬជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា**

☞ ជនបរទេស ឬជនអន្តោប្រវេសន្តរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលស្លាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ ឬអាជ្ញាធរមានសមត្ថកិច្ច អាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលស្លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។

☞ បើចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរខ្មែរដោយយកសូរតាមលំនាំអក្សរឡាតាំង ។

☞ របៀបសរសេរចុះបញ្ជីមរណភាពសម្រាប់ជនបរទេស ឬជនអន្តោប្រវេសន្ត ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីមរណភាពរបស់ពលរដ្ឋខ្មែរដែរ លើកលែងតែចំណុចមួយចំនួន ខាងក្រោម ៖

- សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន្តដែលស្លាប់ (តាមលិខិតឆ្លងដែន)។
- ទីលំនៅឯបរទេស ៖ ត្រូវសរសេរទីលំនៅ នៅប្រទេសដើមរបស់អ្នកស្លាប់ជាអក្សរខ្មែរ ដោយបញ្ជាក់ពីទីលំនៅនៅឯបរទេសឱ្យបានពិតប្រាកដ។
- លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃទី ខែ ឆ្នាំ ៖ ត្រូវសរសេរលេខលិខិតឆ្លងដែនរបស់អ្នកស្លាប់ និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។
- ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃ ខែ ឆ្នាំ ៖ ត្រូវសរសេរលេខទិដ្ឋាការ ឬលេខលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំដែលមានសុពលភាព។

**បញ្ជាក់** ÷ បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬ លិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ត្រីមានសមត្ថកិច្ចភ្លាម។

**រាជធានី ខេត្ត** (១)..................................		**លេខ** (៤)...............................................

**ក្រុង ស្រុក ខណ្ឌ** (២).............................		**សៀវភៅមរណភាពលេខ** (៥)....................

**ឃុំ សង្កាត់** (៣)...................................		**ឆ្នាំ** (៦)...............................................

## បញ្ជីមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់

| | | | | |
|---|---|---|---|---|
| នាមត្រកូល(៧) | | | | ភេទ(៩) |
| នាមខ្លួនសព(៨) | | | | |
| ជាអក្សរឡាតាំង(១០) | នាមត្រកូល | | | |
| | នាមខ្លួនសព | | | |
| សញ្ជាតិ(១១) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត(១២) | | | | |
| ទីកន្លែងកំណើត (១៣) | | | | |
| ស្ថានភាពសព(នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ) (១៤) | | | | |
| មុខរបរមុនពេលស្លាប់ (១៥) | | | | |
| ទីលំនៅមុនពេលស្លាប់ (១៦) | | | | |
| ទីលំនៅឯបរទេស (១៧) | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៨) | | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃខែឆ្នាំ(១៩) | | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (២០) | | | | |
| ទីកន្លែងស្លាប់ (២១) | | | | |
| មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍(២២) | | | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (២៣) | | | ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | |
| ជាអក្សរឡាតាំង (២៥) | | | | |
| សញ្ជាតិ(២៦) | | | | |
| ទីលំនៅបច្ចុប្បន្នរបស់ឪពុកសព (២៧) | | | | |
| នាមត្រកូល និង នាមខ្លួនម្តាយសព (២៨) | | | ថ្ងៃ ខែ ឆ្នាំកំណើត (២៩) | |
| ជាអក្សរឡាតាំង (៣០) | | | | |
| សញ្ជាតិ(៣១) | | | | |
| ទីលំនៅបច្ចុប្បន្នរបស់ម្តាយសព (៣២) | | | | |
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព(៣៣) | | | ភេទ(៣៤) | សញ្ជាតិ(៣៥) |
| ជាអក្សរឡាតាំង (៣៦) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | | | |
| ត្រូវជាអ្វីនឹងសព (៣៨) | | | | |
| មុខរបរបច្ចុប្បន្ន (៣៩) | | | | |
| ទីលំនៅបច្ចុប្បន្ន (៤០) | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (៤១) | | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៤២) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យអ្នកដែលមកសុំជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៤) ធ្វើនៅ................. ថ្ងៃទី......... ខែ............... ឆ្នាំ..........

(៤៣) **ស្នាមមេដៃស្តាំអ្នករាយការណ៍**		(៤៥) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៦) ហត្ថលេខា និងត្រា

### ៤.២.៤. ការសរសេរសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានមរណភាពភ្លោះរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចូលទៅក្នុងសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្ន កុំឱ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីមរណភាព ដោយដកស្រង់យកចំណុចសំខាន់ៗ ពីបញ្ជីមរណភាព ដូចខាងក្រោម ៖

**ក).សម្រាប់ប្រជាពលរដ្ឋខ្មែរ**

១). រាជធានី ខេត្ត ៖ ចម្លងយកពីចំណុចលេខ (១) នៃបញ្ជីមរណភាព។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកពីចំណុចលេខ (២) នៃបញ្ជីមរណភាព។

៣). ឃុំ សង្កាត់ ៖ ចម្លងយកពីចំណុចលេខ (៣) នៃបញ្ជីមរណភាព។

៤). លេខ ៖ ចម្លងយកពីចំណុចលេខ (៤) នៃបញ្ជីមរណភាព។

៥). សៀវភៅមរណភាពលេខ ៖ ចម្លងយកពីចំណុចលេខ (៥) នៃបញ្ជីមរណភាព។

៦). ឆ្នាំ ៖ ចម្លងយកពីចំណុចលេខ (៦) នៃបញ្ជីមរណភាព។

៧). នាមត្រកូល ៖ ចម្លងយកពីចំណុចលេខ (៧) នៃបញ្ជីមរណភាព។

៨). នាមខ្លួនសព ៖ ចម្លងយកពីចំណុចលេខ (៨) នៃបញ្ជីមរណភាព។

៩). ភេទ ៖ ចម្លងយកពីចំណុចលេខ(៩) នៃបញ្ជីមរណភាព។

១០). នាមត្រកូល និងនាមខ្លួនសពជាអក្សរឡាតាំង ៖ ចម្លងយកពីចំណុចលេខ (១១) នៃបញ្ជីមរណភាព។

១១). សញ្ជាតិ ៖ ចម្លងយកពីចំណុចលេខ (១០) នៃបញ្ជីមរណភាព។

១២). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ចម្លងយកពីចំណុចលេខ (១២) នៃបញ្ជីមរណភាព។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកពីចំណុចលេខ (១៣) នៃបញ្ជីមរណភាព។

១៤). ស្ថានភាពសព ៖ ចម្លងយកពីចំណុចលេខ (១៤) នៃបញ្ជីមរណភាព។

១៥). ថ្ងៃ ខែ ឆ្នាំ ដែលស្លាប់ ៖ ចម្លងយកពីចំណុចលេខ (១៨) នៃបញ្ជីមរណភាព។

**ឪពុកសព**

១៦). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកពីចំណុចលេខ (២១) នៃបញ្ជីមរណភាព។

១៧). សញ្ជាតិ ៖ ចម្លងយកពីចំណុចលេខ (២២) នៃបញ្ជីមរណភាព។

១៨). ជាអក្សរឡាតាំង ៖ ចម្លងយកពីចំណុចលេខ (២៤) នៃបញ្ជីមរណភាព។

១៩). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកពីចំណុចលេខ (២៥) នៃបញ្ជីមរណភាព។

**ម្ដាយសព**

២០). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកពីចំណុចលេខ (២៦) នៃបញ្ជីមរណភាព។

២១). សញ្ជាតិ ៖ ចម្លងយកពីចំណុចលេខ (២៧) នៃបញ្ជីមរណភាព។

២២). ជាអក្សរឡាតាំង ៖ ចម្លងយកពីចំណុចលេខ (២៩) នៃបញ្ជីមរណភាព។

២៣). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកពីចំណុចលេខ (៣០) នៃបញ្ជីមរណភាព។

២៤). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ ចម្លងយកពីចំណុចលេខ (៤០) នៃបញ្ជីមរណភាព។

២៥). មន្ត្រីអត្រានុកូលដ្ឋាន ៖ ចំណុចលេខ (៤១) នៃបញ្ជីមរណភាព (ដាក់ថាមេឃុំ/ចៅសង្កាត់ ឬមេឃុំស្តីទី / ចៅសង្កាត់ស្តីទី)។

២៦). ហត្ថលេខា ត្រា និងឈ្មោះមន្ត្រីអត្រានុកូលដ្ឋាន៖ មើលចំណុចលេខ (៤២) នៃបញ្ជីមរណភាព។

**ខ).សម្រាប់ជនបរទេស ឬជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា**

១). រាជធានី ខេត្ត ៖ ចម្លងយកពីចំណុចលេខ (១) នៃបញ្ជីមរណភាព។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកពីចំណុចលេខ (២) នៃបញ្ជីមរណភាព។

៣). ឃុំ សង្កាត់ ៖ ចម្លងយកពីចំណុចលេខ (៣) នៃបញ្ជីមរណភាព។

៤). លេខ ៖ ចម្លងយកពីចំណុចលេខ (៤) នៃបញ្ជីមរណភាព។

៥). សៀវភៅមរណភាពលេខ ៖ ចម្លងយកពីចំណុចលេខ (៥) នៃបញ្ជីមរណភាព។

៦). ឆ្នាំ ៖ ចម្លងយកពីចំណុចលេខ (៦) នៃបញ្ជីមរណភាព។

៧). នាមត្រកូល ៖ ចម្លងយកពីចំណុចលេខ (៧) នៃបញ្ជីមរណភាព។

៨). នាមខ្លួនសព ៖ ចម្លងយកពីចំណុចលេខ (៨) នៃបញ្ជីមរណភាព។

៩). ភេទ ៖ ចម្លងយកពីចំណុចលេខ (៩) នៃបញ្ជីមរណភាព។

១០). នាមត្រកូល និងនាមខ្លួនសពជាអក្សរឡាតាំង ៖ ចម្លងយកពីចំណុចលេខ (១០) នៃបញ្ជីមរណភាព។

១១). សញ្ជាតិ ៖ ចម្លងយកពីចំណុចលេខ (១១) នៃបញ្ជីមរណភាព។

១២). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ចម្លងយកពីចំណុចលេខ (១២) នៃបញ្ជីមរណភាព។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកពីចំណុចលេខ (១៣) នៃបញ្ជីមរណភាព។

១៤). ស្ថានភាពសព ៖ ចម្លងយកពីចំណុចលេខ (១៤) នៃបញ្ជីមរណភាព។

១៥). ថ្ងៃ ខែ ឆ្នាំ ដែលស្លាប់ ៖ ចម្លងយកពីចំណុចលេខ (២០) នៃបញ្ជីមរណភាព។

**ឪពុកសព**

១៦). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកពីចំណុចលេខ (២៣) នៃបញ្ជីមរណភាព។

១៧). សញ្ជាតិ ៖ ចម្លងយកពីចំណុចលេខ (២៦) នៃបញ្ជីមរណភាព។

១៨). ជាអក្សរឡាតាំង ៖ ចម្លងយកពីចំណុចលេខ (២៥)នៃបញ្ជីមរណភាព។

១៩). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកពីចំណុចលេខ (២៤) នៃបញ្ជីមរណភាព។

**ម្ដាយសព**

២០). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកពីចំណុចលេខ (២៨) នៃបញ្ជីមរណភាព។

២១). សញ្ជាតិ ៖ ចម្លងយកពីចំណុចលេខ (៣១) នៃបញ្ជីមរណភាព។

២២). ជាអក្សរឡាតាំង ៖ ចម្លងយកពីចំណុចលេខ (៣០) នៃបញ្ជីមរណភាព។

២៣). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកពីចំណុចលេខ (២៩) នៃបញ្ជីមរណភាព។

២៤). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ ចម្លងយកពីចំណុចលេខ (៤៤) នៃបញ្ជីមរណភាព។

២៥). មន្ត្រីអត្រានុកូលដ្ឋាន ៖ ចំណុចលេខ (៤៥) នៃបញ្ជីមរណភាព (ដាក់ថាមេឃុំ/ចៅសង្កាត់ ឬមេឃុំស្តីទី / ចៅសង្កាត់ស្តីទី)។

២៦). ហត្ថលេខា ត្រា និងឈ្មោះមន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចលេខ (៤៦) នៃបញ្ជីមរណភាព។

**បញ្ជាក់** ÷

☞ ការប្រគល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ក្រោយពីសរសេរ ចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹករួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រមរណភាពច្បាប់ដើមនេះ ទៅឱ្យអ្នកមករាយការណ៍អំពីមរណភាពដែលសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំឱ្យរក្សាទុកដាក់ឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចចេញសំបុត្រមរណភាពច្បាប់ដើម ជូនជាលើកទីពីរបានទេ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រមរណភាពច្បាប់ដើម គឺជាឯកសារដែលមានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ដូច្នេះគួរធ្វើសេចក្តីចម្លងសំបុត្រមរណភាពឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

☞ នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងចេញសំបុត្រមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

**ឧទាហរណ៍** ៖ នៅផ្នែកឪពុកត្រង់ខ្ទង់ “នាមត្រកូល និងនាមខ្លួន” នៃសំបុត្រកំណើតបានសរសេរថា “មិនស្គាល់” ត្រូវសរសេរថា “មិនស្គាល់” ដូចគ្នានេះដែរ នៅផ្នែកឪពុករបស់សាមីខ្លួនត្រង់ខ្ទង់ “នាមត្រកូល និងនាមខ្លួន” នៃបញ្ជីមរណភាព និងសំបុត្រមរណភាព។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** (១) ---- *កណ្តាល* ------ **លេខ** (៤)--------- *០៣* --------------------

**ក្រុង ស្រុក ខណ្ឌ** (២) ----- *ល្វាឯម* ---- **សៀវភៅមរណភាពលេខ** (៥)--០១/២០១៤--

**ឃុំ សង្កាត់** (៣) ----- *កោះកែវ* ---- **ឆ្នាំ** (៦)----------- *២០១៤* ------------------

# សំបុត្រមរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | *ស៊ីម* | ភេទ (៩) |
| នាមខ្លួនសព (៨) | | *វណ្ណា* | *ស្រី* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | *SIM* | |
| | នាមខ្លួនសព | *VANNA* | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | .........ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា* ......................................................... | |
| ស្ថានភាពសព (១៤)<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *មានប្តី* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៥) | | *ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤* | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (១៦) | | *ស៊ីម សារឿន* | សញ្ជាតិ (១៧) |
| ជាអក្សរឡាតាំង (១៨) | | SIM SAROEUN | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | |
| នាមត្រកូល និង នាមខ្លួនម្តាយសព (២០) | | *ស្រី នាង* | សញ្ជាតិ (២១) |
| ជាអក្សរឡាតាំង (២២) | | SREY NEANG | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | |

(២៤) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២៦) *ហត្ថលេខា និងត្រា*

*ប៉ិត ប៊ុន*

## ៤.៣. សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព

☞ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ សង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ហើយត្រូវបោះត្រាផង ។

☞ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌសាមី ឬនៅក្រសួងមហាផ្ទៃ

- បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុ-កូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង ។
- បើសុំចម្លង ឬសម្រង់នៅក្រសួងមហាផ្ទៃត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬអគ្គនាយករងទទួលបន្ទុក ឬប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន ដែលធ្វើប្រតិភូកម្មឱ្យ និងបោះត្រាផង ។

☞ ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅស្ថានទូតស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ៖

- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូតស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ (ភារធារី) ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅទីនោះ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្រមរណភាព ត្រូវយកសំបុត្រមរណភាពច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រមរណ-ភាពមកជាមួយ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ត្រូវយកសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពមកជាមួយ ។

**បញ្ជាក់** ៖ ករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចមកសុំចម្លងបាន ត្រូវមានល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

- រាយការណ៍ជាលាយលក្ខអក្សរឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃការបាត់បង់

- បញ្ជាក់ពីឈ្មោះឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន ដើម្បីមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានងាយស្រួលក្នុងការស្វែងរក ។

### ៤.៣.១. ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព

☞ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ដែលអ្នកមកសុំចម្លងយកមក ដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពនោះ ពិតជាត្រឹមត្រូវដែលបោះពុម្ព ដោយក្រសួងមហាផ្ទៃ មែនដែរឬទេ?
- ផ្ទៀងផ្ទាត់សំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពនោះ ជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាព ឬក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព នូវចំណុចមួយចំនួនដូចខាងក្រោម :
  - ឈ្មោះឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តសាមី
  - ឆ្នាំដែលអនុវត្តនៃសៀវភៅអត្រានុកូលដ្ឋាន
  - លេខសៀវភៅអត្រានុកូលដ្ឋាន
  - លេខបញ្ជីអត្រានុកូលដ្ឋាន

☞ នៅពេលពិនិត្យសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព ឃើញថាជាសំបុត្រច្បាប់ដើមពិតប្រាកដហើយ ទើបមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព។

☞ ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព ដោយចម្លងចេញពី ៖

- សៀវភៅអត្រានុកូលដ្ឋានមរណភាព បើសុំចម្លងសំបុត្រមរណភាព។
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព បើសុំចម្លងសំបុត្របញ្ជាក់មរណភាព។

☞ របៀបសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព ដូចខាងក្រោម ៖

១). លេខរៀង ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពីលេខ០១ ជាបន្តបន្ទាប់។

២). ថ្ងៃខែឆ្នាំចេញសេចក្តីចម្លង ៖ ត្រូវចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរតាមគ្រិស្តសករាជ គឺជាថ្ងៃ ខែ ឆ្នាំ ដែលមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ចុះហត្ថលេខា លើសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព។

៣). ចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព ៖

- បើចម្លងសំបុត្រមរណភាព ត្រូវសរសេរក្នុងខ្ទង់នេះថា "ចម្លងសំបុត្រមរណភាព" ។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវសរសេរក្នុងខ្ទង់នេះថា "ចម្លងសំបុត្របញ្ជាក់មរណភាព"

**សៀវភៅ**

៤). លេខ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (៥) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (៥) នៃបញ្ជីបញ្ជាក់មរណភាព។

៥). ឃុំ សង្កាត់ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (៣) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (៣) នៃបញ្ជីបញ្ជាក់មរណភាព។

**សំបុត្រ**

៦). លេខ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (៤) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (៤) នៃបញ្ជីបញ្ជាក់មរណភាព។

៧). ចុះថ្ងៃ ខែ ឆ្នាំ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (៤០) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (៤៥) នៃបញ្ជីបញ្ជាក់មរណភាព។

**សព**

៨). នាមត្រកូល និងនាមខ្លួន ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (៧) និងលេខ (៨) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (៧-៨) នៃបញ្ជីបញ្ជាក់មរណភាព។

៩). ភេទ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (៩) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (៩) នៃបញ្ជីបញ្ជាក់មរណភាព។

១០). សញ្ជាតិ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (១០) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (១០) នៃបញ្ជីបញ្ជាក់មរណភាព។

១១). ថ្ងៃ ខែ ឆ្នាំកំណើត ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (១២) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (១២) នៃបញ្ជីបញ្ជាក់មរណភាព។

១២). ថ្ងៃ ខែ ឆ្នាំស្លាប់ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចលេខ (១៨) នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចលេខ (១៨) នៃបញ្ជីបញ្ជាក់មរណភាព។

**អ្នកសុំចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព**

១៣). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួន របស់អ្នកមកសុំចម្លងសំបុត្រមរណភាព ឬអ្នកមកសុំចម្លងសំបុត្របញ្ជាក់មរណភាព។

១៤). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរទីលំនៅបច្ចុប្បន្នរបស់អ្នកមកសុំចម្លងសំបុត្រមរណភាព ឬអ្នកមកសុំចម្លងសំបុត្របញ្ជាក់មរណភាព ដោយសរសេរលេខផ្ទះ លេខផ្លូវ (បើសិនជាមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និង ប្រទេស។

១៥). ត្រូវជាអ្វីនឹងសព ៖ ត្រូវសរសេរពីការពាក់ព័ន្ធ ជាឪពុក ម្តាយ កូន សាច់ញាតិសន្តាន ឬអ្នកជិតខាងនៃអ្នកស្លាប់។ **ឧទាហរណ៍:** បើជាកូនបង្កើតសរសេរ "កូនបង្កើត" បើជាប្រពន្ធសរសេរ "ប្រពន្ធ"។

១៦). ស្នាមមេដៃស្តាំ ៖ ក្រោយពីសរសេរបំពេញគ្រប់ខ្ទង់រួចហើយ ត្រូវឱ្យអ្នកមកសុំចម្លង ផ្តិតមេដៃស្តាំ។

**មន្ត្រីចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព**

១៧). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនអ្នកដែលចុះហត្ថលេខាលើសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព។

១៨). មុខងារ ៖ ត្រូវសរសេរមុខងាររបស់មន្ត្រីដែលមានឈ្មោះនៅចំណុច១៧ ៖

- អាចសរសេរ “មេឃុំ” ឬ “ចៅសង្កាត់” បើគាត់ជាមេឃុំ ឬចៅសង្កាត់។ អាចសរសេរ “មេឃុំស្តីទី” ឬ “ចៅសង្កាត់ស្តីទី” បើគាត់បានទទួលការផ្ទេរសិទ្ធិ។
- អាចសរសេរ “ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ” បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាក្រុង ស្រុក ខណ្ឌ។
- អាចសរសេរ “ប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន” បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលារាជធានី ខេត្ត ។
- អាចសរសេរ “មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន” បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅក្រសួងមហាផ្ទៃ។

១៩). ចំនួនសន្លឹកចម្លង ៖ ត្រូវសរសេរចំនួនសន្លឹកនៃសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព ដែលបានចម្លង ដោយសរសេរជាលេខខ្មែរ។

២០). សេចក្តីផ្សេងៗ ៖ បើមានករណីពិសេសដែលគ្មានរៀបរាប់ក្នុងចំណុចទាំង១៩នោះទេ ត្រូវសរសេរក្នុងសេចក្តីផ្សេងៗនេះ។ បើគ្មានករណីពិសេសទេ មិនត្រូវសរសេរអ្វីឡើយ ដោយទុកឱ្យនៅទំនេរ។

**ឧទាហរណ៍** ៖ ការចម្លងលើកទី២ ស្នាមមេដៃឆ្វេង (បើអ្នកមកសុំចម្លងពុំមានមេដៃស្តាំ) ។ល។

**ឧទាហរណ៍ ៤.៣** ៖ ការសរសេរសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព នៅសាលាឃុំ សង្កាត់ តាមឧទាហរណ៍ ដូចខាងក្រោម ៖

ថ្ងៃច័ន្ទ ទី១៧ ខែមីនា ឆ្នាំ២០១៤ លោក សោម សារិទ្ធ បានទៅសុំចម្លងសំបុត្រមរណភាពរបស់ម្តាយគាត់ឈ្មោះ ស៊ឹម វណ្ណា ចំនួន០៥សន្លឹក ដោយកាន់យកទៅជាមួយនូវសំបុត្រមរណភាពច្បាប់ដើមរបស់ម្តាយគាត់ លេខ ០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពលេខ ០១/២០១៤ ដើម្បីបង្ហាញមន្ត្រីអត្រានុកូលដ្ឋាន ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល។

លោក សោម សារិទ្ធ បច្ចុប្បន្នរស់នៅភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល។

មន្ត្រីអត្រានុកូលដ្ឋានឃុំកោះកែវ ប៊ុត ប៊ុន។

**ឧទាហរណ៍ ៤.៤** ÷ ការសរសេរចូលក្នុងសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព នៅសាលាក្រុង ស្រុក ខណ្ឌ តាមឧទាហរណ៍ដូចខាងក្រោម ៖

ថ្ងៃច័ន្ទ ទី១៣ ខែមករា ឆ្នាំ២០១៤ លោក ម៉ែន សាមឿន បានទៅសុំចម្លងសំបុត្របញ្ជាក់មរណភាពរបស់ឪពុកគាត់ចំនួន០៥សន្លឹក នៅសាលាស្រុកកោះធំ ខេត្តកណ្ដាល ដោយបានកាន់យកទៅជាមួយនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើមរបស់ឪពុកគាត់ លេខ០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពលេខ០១/២០០៦ ដើម្បីបង្ហាញមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន នៅស្រុកកោះធំ ។

លោក ម៉ែន សាមឿន បច្ចុប្បន្នរស់នៅភូមិចុងព្រែក ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល ។

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុកកោះធំ ឈ្មោះ អ៊ូច ប៊ុនគីម ។

លេខ និងថ្ងៃខែឆ្នាំចេញសេចក្ដីចម្លងសំបុត្របញ្ជាក់មរណភាពនេះ (របស់ស្រុកកោះធំ) ៖ ០១ ក.ធ.ប.ម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ។

អភិបាលស្រុកកោះធំឈ្មោះ ខៀវ សំអាត ។

# សៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ ចេញសេចក្ដីចម្លង | ចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | សៀវភៅ | | សំបុត្រ | | សព | | | | | | អ្នកសុំចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | | មន្ត្រីចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃ ខែ ឆ្នាំ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ ខែ ឆ្នាំស្លាប់ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងសព | ស្នាមមេដៃស្ដាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្ដីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤* | *ចម្លងសំបុត្រមរណភាព* | *០១/២០១៤* | *កោះកែវ* | *០៣* | *ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤* | *ស៊ីម វណ្ណា* | *ស្រី* | *ខ្មែរ* | *ថ្ងៃច័ន្ទ ទី២៦ ខែតុលា ឆ្នាំ១៩៣១* | *ថ្ងៃច័ន្ទ ទី២០ ខែមករា ឆ្នាំ២០១៤* | *សោម សារិទ្ធ* | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *កូនបង្កើត* | | *ប៉ិត ប៊ុន* | *មេឃុំ* | *០៥ សន្លឹក* | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

# សៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព (នៅសាលាក្រុង ស្រុក ខណ្ឌ ឬនៅក្រសួងមហាផ្ទៃ)

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ ចេញសេចក្តីចម្លង | ចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | សៀវភៅ | | សំបុត្រ | | សព | | | | | អ្នកសុំចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | | មន្ត្រីចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃ ខែ ឆ្នាំ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ ខែ ឆ្នាំស្លាប់ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងសព | ស្នាមមេដៃ ស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤* | *ចម្លងសំបុត្របញ្ជាក់មរណភាព* | *០១/២០០៦* | *ព្រែកស្តី* | *០៥* | *ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦* | *ម៉ែន សាម៉ន* | *ប្រុស* | *ខ្មែរ* | *ថ្ងៃសុក្រ ទី០៣ ខែមីនា ឆ្នាំ១៩៣១* | *ថ្ងៃពុធ ទី១៥ ខែមករា ឆ្នាំ១៩៩៧* | *ម៉ែន សាមឿន* | *ភូមិចុងព្រែក ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *កូនបង្កើត* | | *អ៊ូច ប៊ុនគីម* | *ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ* | *០៥ សន្លឹក* | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

### ៤.៣.២. របៀបសរសេរសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព

☞ នៅពេលសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាពចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវសរសេរចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព។

☞ របៀបសរសេរសេចក្តីចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព អនុវត្តដូចគ្នានឹងការសរសេរសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពច្បាប់ដើមដែរ។

☞ ចំពោះការសុំចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវមានការបញ្ជាក់មួយចំនួន ដូចខាងក្រោម ៖

| |
|---|
| លេខ (ក)...................... |
| យើង (ខ)............................................................ |
| បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា |
| របស់លោក លោកស្រី (គ)................ ជាមន្ត្រីរក្សាសៀវភៅ |
| អត្រានុកូលដ្ឋាន (ឃ)............................ពិតប្រាកដមែន។ |
| (ង) ធ្វើនៅ............... ថ្ងៃទី........ ខែ.............. ឆ្នាំ........ |
| (ច) ហត្ថលេខា និងត្រា |

ក). លេខ ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពី០១ ជាបន្តបន្ទាប់រហូតដល់ដំណាច់ឆ្នាំ។ នៅឆ្នាំថ្មី ត្រូវអនុវត្ត ចុះលេខថ្មី ចាប់ពីលេខ០១ដដែល។ នៅសាលាក្រុង ស្រុក ខណ្ឌ និងនៅក្រសួងមហាផ្ទៃត្រូវមានសៀវភៅចុះលេខចេញដោយឡែក សម្រាប់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន។

ខ). ត្រូវសរសេរ "អភិបាលក្រុង ស្រុក ខណ្ឌ......(ឈ្មោះក្រុង ស្រុក ខណ្ឌ)........." បើនៅក្រសួងមហាផ្ទៃ ត្រូវសរសេរ "អគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក ឬប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន (ឈ្មោះអគ្គនាយកដ្ឋាន ឬឈ្មោះនាយកដ្ឋានអត្រានុកូលដ្ឋាន)"។

គ). ឈ្មោះមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន។

ឃ). ត្រូវសរសេរ "ក្រុង ស្រុក ខណ្ឌ...........(ឈ្មោះក្រុង ស្រុក ខណ្ឌ)..........." ឬ បើនៅក្រសួងមហាផ្ទៃ ត្រូវសរសេរ "ឈ្មោះអគ្គនាយកដ្ឋាន ឬឈ្មោះនាយកដ្ឋានអត្រានុកូលដ្ឋាន" ។

ង). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ ត្រូវសរសេរឈ្មោះក្រុង ស្រុក ខណ្ឌ ឬរាជធានីភ្នំពេញ និងចុះថ្ងៃទីជា លេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរតាម គ្រិស្តសករាជ។

ច). ហត្ថលេខា និងត្រា ៖ ហត្ថលេខារបស់អភិបាលក្រុង ស្រុក ខណ្ឌ ឬអគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក ឬប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន និងបោះត្រា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** (១) ---- *កណ្តាល* -----
**ក្រុង ស្រុក ខណ្ឌ** (២) ----- *ល្វាឯម* ------
**ឃុំ សង្កាត់** (៣) ----- *កោះកែវ*-----

# សេចក្តីចម្លងសំបុត្រមរណភាព

| ចម្លងសំបុត្រមរណភាពចេញពី | (៤) សៀវភៅមរណភាព<br>លេខ៖ *០១/២០១៤* | (៥) សំបុត្រមរណភាព<br>លេខ *០៣* ចុះថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤* |
|---|---|---|
| នាមត្រកូល (៦) | *ស៊ឹម* | ភេទ(៨) |
| នាមខ្លួនសព (៧) | *វណ្ណា* | *ស្រី* |
| ជាអក្សរឡាតាំង(៩) នាមត្រកូល | *SIM* | |
| ជាអក្សរឡាតាំង(៩) នាមខ្លួនសព | *VANNA* | |
| សញ្ជាតិ (១០) | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | .........ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា*<br>............................................................................................... | |
| ស្ថានភាពសព (១៣)<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | *មានប្តី* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤) | *ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤* | |
| នាមត្រកូល និងនាមខ្លួនឪពុកសព (១៥) | *ស៊ឹម សារឿន* | សញ្ជាតិ(១៦) |
| ជាអក្សរឡាតាំង (១៧) | SIM SAROEUN | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៨) | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | |
| នាមត្រកូល និងនាមខ្លួនម្តាយសព (១៩) | *ស្រី នាង* | សញ្ជាតិ(២០) *ខ្មែរ* |
| ជាអក្សរឡាតាំង (២១) | *SREY NEANG* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២២) | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | |

(២៣) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *១៧* ខែ *មីនា* ឆ្នាំ *២០១៤*

(២៤) **មន្ត្រីអត្រានុកូលដ្ឋាន**

*មេឃុំ*

(២៥) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**~~រាជធានី~~ ខេត្ត** (១) ----- *កណ្ដាល* -----
**~~ក្រុង~~ ស្រុក ~~ខណ្ឌ~~** (២) ----- *កោះធំ* ------
**ឃុំ ~~សង្កាត់~~** (៣) --------ព្រែកស្តី------

## សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព

| | | | |
|---|---|---|---|
| ចម្លងសំបុត្របញ្ជាក់មរណភាពចេញពី | | (៤) សៀវភៅបញ្ជាក់មរណភាព លេខ៖ *០១/២០០៦* | (៥) សំបុត្របញ្ជាក់មរណភាព លេខ០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ |
| នាមត្រកូល (៦) | | *ម៉ែន* | ភេទ(៨) |
| នាមខ្លួនសព (៧) | | *សាម៉ន* | *ប្រុស* |
| ជាអក្សរឡាតាំង(៩) | នាមត្រកូល | MEN | |
| | នាមខ្លួនសព | SAMAN | |
| សញ្ជាតិ (១០) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ សុក្រ ទី ០៣ ខែ មីនា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | .... ភូមិវាលស្បូវ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា | |
| ស្ថានភាពសព (១៣)<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *ពោះម៉ាយ* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤) | | *ថ្ងៃ ពុធ ទី ១៥ ខែ មករា ឆ្នាំ ១៩៩៧* | |
| នាមត្រកូល និងនាមខ្លួនឪពុកសព (១៥) | | *ម៉ែន សាម៉ែន* | សញ្ជាតិ(១៦) |
| ជាអក្សរឡាតាំង (១៧) | | MEN SAMEN | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៨) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១០* | |
| នាមត្រកូល និងនាមខ្លួនម្តាយសព (១៩) | | *សួន ប្រាថ្នា* | សញ្ជាតិ(២០) |
| ជាអក្សរឡាតាំង (២១) | | SUON PRATHNA | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២២) | | *ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩១២* | |

លេខ(ក)..... *០១ ក.ធ.ប.ម* ...........
យើង(ខ).... *អភិបាលស្រុកកោះធំ* .................................
បានឃើញនិងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា
របស់លោក(គ)..... *អ៊ុច ប៊ុនគីម*....... ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន(ឃ)......... ស្រុកកោះធំ........ពិតប្រាកដមែន។
(ង) ធ្វើនៅកោះធំ..... ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤

(ច) *ហត្ថលេខា និងត្រា*
*ខៀវ សំអាត*

(២៤) ធ្វើនៅ...កោះធំ.... ថ្ងៃទី *១៤* ខែ *មករា* ឆ្នាំ *២០១៤*
(២៥) **មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**
*ហត្ថលេខា*
*អ៊ុច ប៊ុនគីម*

## ៤.៣.៣. សេចក្តីសម្រង់សំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព

☞ សម្រង់សំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារតាមសំណើរបស់អ្នកមកសុំស្រង់ប៉ុណ្ណោះ។

## ៤.៣.៤.តារាងសម្គាល់លេខរៀងប្រភេទជំងឺ ឬមូលហេតុនៃទៀតនៃមរណភាព

| ល.រ | រាយប្រភេទជំងឺ ឬមូលហេតុនៃមរណភាព |
|---|---|
| ១ | ជំងឺផ្លូវដង្ហើម |
| ២ | ជំងឺលើសឈាម |
| ៣ | គ្រោះថ្នាក់ចរាចរ |
| ៤ | ជំងឺទឹកនោមផ្អែម |
| ៥ | ជំងឺបេះដូង |
| ៦ | ជំងឺរបេង |
| ៧ | ជំងឺអេដស៍ |
| ៨ | ជំងឺរលាកស្រោមខួរ |
| ៩ | ជំងឺគ្រុនចាញ់ |
| ១០ | ជំងឺរាក |
| ១១ | ជំងឺគ្រុនឈាម |
| ១២ | ជំងឺអាសន្នរោគ |
| ១៣ | ជំងឺគ្រុនពោះវៀន |
| ១៤ | ជំងឺមហារីកថ្លើម |
| ១៥ | ជំងឺមហារីកសួត |
| ១៦ | ជំងឺមហារីកមាត់ស្បូន |
| ១៧ | មរណភាពមាតា |
| ១៨ | ជំងឺផ្តាសាយថ្មី |
| ១៩ | ជំងឺផ្តាសាយបក្សី |
| ២០ | ជំងឺគ្រុនឈិក |
| ២១ | គ្រោះថ្នាក់ផ្សេងៗ (ក្រៅពីគ្រោះថ្នាក់ចរាចរ) |
| ២២ | ជំងឺផ្សេងៗ |